# ថ្នាំសម្រាប់ព្យាបាលជំងឺ COVID-19 មានផ្តល់ជូនហើយឥឡូវ



## សូមទំនាក់ទំនងទៅ
### អ្នកផ្តល់សេវាកម្មថែទាំសុខភាព

1. **ប្រសិនបើអ្នកធ្វើតេស្តទទួលលទ្ធផលវិជ្ជមានសម្រាប់ជំងឺ** COVID-19 សូមទូរស័ ព្ទទៅអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាព ឬមជ្ឈមណ្ឌលសុខភាពសាធារណៈតាមរយៈលេខ 1-833-540-0473។
2. **និយាយអំពីការព្រួយបារម្ភផ្នែកសុខភាពណាមួយ និងថ្នាំ**ដែលអ្នកកំពុងប្រើប្រាស់ **នាពេលបច្ចុប្បន្ន**។ ប្រសិនបើ អ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សូមទៅទទួលវេជ្ជបញ្ជាសម្រាប់ថ្នាំព្យាបាលជំងឺ COVID-19 នេះ។
3. **ទទួលថ្នាំតាមវេជ្ជបញ្ជានៅឱសថស្ថាន** ឬក៏ស្នើសុំឱ្យផ្ញើថ្នាំនេះទៅផ្ទះរបស់អ្នកដោយផ្ទាល់ តាមរយៈសេវាកម្មថែទាំសុខភាពពីចម្ងាយរបស់សុខភាពសាធារណៈ (Public Health Telehealth)។
4. **ចាប់ផ្តើមការព្យាបាល** ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

## សូមចូលទៅកាន់
### ទីតាំង ធ្វើ តេស្តដើ ម្បី ព្យាបាល




1. ស្វែងរកទីតាំង ធ្វើតេស្តដើម្បីព្យាបាល (Test to Treat) ដែលជាដៃគូមួយដោយទូរស័ព្ទទៅលេខ 1-833-540-0473 **ឬចូលទៅកាន់គេហទំព័រ** ph.lacounty.gov/covidmedicines
2. **ទៅធ្វើតេស្តរកមេរោគ**នៅនឹងទីតាំងផ្ទាល់ ឬនាំយកលទ្ធផលពីឱសថស្ថានអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាព ឬការធ្វើតេស្តនៅផ្ទះទៅ។
3. **ប្រសិនបើអ្នកធ្វើតេស្តទទួលលទ្ធផលវិជ្ជមានសម្រាប់ជំងឺ** COVID-19 សូមនិយាយអំពីការព្រួយបារម្ភផ្នែកសុខភាពណាមួយ និងថ្នាំដែលអ្នកកំពុងប្រើប្រាស់នាពេលបច្ចុប្បន្ន។ ប្រសិនបើអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ សូមទៅទទួលវេជ្ជបញ្ជាសម្រាប់ថ្នាំព្យាបាលជំងឺ COVID-19 នេះ។
4. **ទទួលថ្នាំតាមវេជ្ជបញ្ជា**ហើយ**ចាប់ផ្តើមការព្យាបាល** ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

អ្នកក៏អាចទូរស័ព្ទទៅមជ្ឈមណ្ឌលសុខភាពសាធារណៈតាមរយៈទូរស័ព្ទលេខ 1-833-540-0473 និងប្រើប្រាស់សេវាកម្មថែទាំសុខភាពពីចម្ងាយរបស់សុខភាពសាធារណៈ ប្រសិនបើអ្នកបានធ្វើតេស្តទទួលលទ្ធផលវិជ្ជមានរួចហើយ និងកំពុងស្វែងរកលទ្ធភាពទទួលបានការវាយតម្លៃនិងការព្យាបាល។

ថ្នាំទាំងនេះគឺ **មិនមែនជាការជំនួសថ្នាំបង្ការជំងឺ COVID-19 នោះទេ** ហើយក៏ **មិនផ្លាស់ប្តូរសេចក្តីណែនាំស្តីពីការដាក់ខ្លួនឱ្យនៅដាច់ដោយឡែកនិងការធ្វើចត្តាឡីស័ក** នោះដែរ។ ប្រសិនបើអ្នកមានសិទ្ធិទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 អ្នកគួរតែទៅទទួលចាក់ថ្នាំបង្ការឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។